# ព្រះរាជក្រឹត្យ

## ស្តីពី

## និមិត្តសញ្ញា ត្រា រូបសញ្ញា សញ្ញាសក្តិ និង ឯកសណ្ឋាននៃក្រុមប្រឹក្សាធម្មនុញ្ញ

នស/រកត/១០០១/៣៥៩

## យើង

## ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ

## រាជហរិវង្ស ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍

## និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ

## ព្រះចៅក្រុងកម្ពុជាធិបតី

-បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃ ព្រះរាជាណាចក្រកម្ពុជា

-បានទ្រង់យល់ព្រះរាជក្រមលេខ ជស/រកម/០៤៩៨/០៦ ចុះថ្ងៃទី ០៨ ខែ មេសា ឆ្នាំ១៩៩៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅ នៃ ក្រុមប្រឹក្សាធម្មនុញ្ញ

-តាមសេចក្តីក្រាបបង្គំទូលស្នើសុំរបស់ប្រធានក្រុមប្រឹក្សាធម្មនុញ្ញ ដែលបានការឯកភាពពីក្រុមប្រឹក្សាធម្មនុញ្ញក្នុងសម័យប្រជុំពេញអង្គនាថ្ងៃទី ០៩ ខែ តុលា ឆ្នាំ២០០១ ។

## ត្រាស់បង្គាប់

### ជំពូកទី១

### អំពីនិមិត្តសញ្ញា

**មាត្រា ១.-**

អនុញ្ញាតឱ្យក្រុមប្រឹក្សាធម្មនុញ្ញ បន្តប្រើប្រាស់និមិត្តសញ្ញាដែលមានរួចហើយ សំរាប់សម្គាល់ក្រុមប្រឹក្សាធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា។

**មាត្រា ២.-**

និមិត្តសញ្ញា នៃ ក្រុមប្រឹក្សាធម្មនុញ្ញ មានរូបព្រះព្រហ្មមានព្រះភ័ក្រ្ត ៤ និង ព្រះហស្ត ៤ កាន់កេតនភណ្ឌ គង់លើបល្ល័ង្ក ។

ព្រះព្រហ្មជានិមិត្តរូបនៃអ្នកបង្កើតលោក ។

ព្រះភ័ក្ត្រព្រះព្រហ្មតំណាងឱ្យព្រហ្មវិហារធម៌ទាំងបួនគឺ ÷ មេត្តា ករុណា មុទិតា និង ឧបេក្ខា ។

- ព្រះហស្តឆ្វេងខាងលើកាន់ផ្កាឈូក : តំណាងការកកើត
- ព្រះហស្តឆ្វេងខាងក្រោមកាន់សាស្ត្រា: តំណាងគម្ពីរ ក្បួន ច្បាប់
- ព្រះហស្តស្តាំខាងលើកាន់ផ្កា : តំណាងឱ្យការរំងាប់អារម្មណ៍ ការឧទ្ទិសកុសល ការចំរើនភាវនា រកអំពើល្អ ផ្លូវធម៌ ផ្លូវលោក
- ព្រះហស្តស្តាំខាងក្រោមកាន់ពួចទឹក : តំណាងទឹកអម្រឹតប្រោះព្រំ ឱ្យសុខសប្បាយត្រជាក់ត្រជុំ ឱ្យរស់ ។

មាត្រា ៣ .-

គំរូនិមិត្តសញ្ញានៃក្រុមប្រឹក្សាធម្មនុញ្ញ មានតម្កល់ទុកនៅអគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ ( ដូចក្នុងឧបសម្ព័ន្ធទី ១ នៃព្រះរាជក្រឹត្យនេះ ) ។

## ជំពូកទី ២

## អំពីត្រារបស់ក្រុមប្រឹក្សាធម្មនុញ្ញ

មាត្រា ៤ .-

អនុញ្ញាតឱ្យក្រុមប្រឹក្សាធម្មនុញ្ញ បន្តប្រើប្រាស់ត្រាដែលមានរូចហើយ សំរាប់ប្រថាប់លើឯកសារផ្លូវការរបស់ក្រុមប្រឹក្សាធម្មនុញ្ញ ។

មាត្រា ៥ .-

ត្រារបស់ក្រុមប្រឹក្សាធម្មនុញ្ញ មានលក្ខណៈដូចខាងក្រោម ÷

- រង្វង់ខាងក្នុងមាននិមិត្តសញ្ញាក្រុមប្រឹក្សាធម្មនុញ្ញ
- នៅក្នុងហាមមណ្ឌល :
  - ផ្នែកខាងលើមានចារឹកអក្សរ " **ព្រះរាជាណាចក្រកម្ពុជា** "
  - ផ្នែកខាងក្រោមមានចារឹកអក្សរ " **ក្រុមប្រឹក្សាធម្មនុញ្ញ** "

មាត្រា ៦ .-

គំរូត្រារបស់ក្រុមប្រឹក្សាធម្មនុញ្ញ មានតម្កល់ទុកនៅក្រសួងមហាផ្ទៃ ។

មាត្រា ៧ .-

ខ្នាត និង គំរូត្រារបស់ក្រុមប្រឹក្សាធម្មនុញ្ញ មានដូចក្នុងឧបសម្ព័ន្ធទី ២ នៃព្រះរាជក្រឹត្យនេះ ។

## ជំពូកទី ៣
## អំពីរូបសញ្ញា នៃ ក្រុមប្រឹក្សាធម្មនុញ្ញ

**មាត្រា ៨ .-**

បង្កើតរូបសញ្ញានៃក្រុមប្រឹក្សាធម្មនុញ្ញ សំរាប់ជូនក្រុមប្រឹក្សាធម្មនុញ្ញប្រើប្រាស់ និង ជូនភ្ញៀវកិត្តិយសរបស់ក្រុមប្រឹក្សាធម្មនុញ្ញ ។

**មាត្រា ៩ .-**

រូបសញ្ញា នៃ ក្រុមប្រឹក្សាធម្មនុញ្ញមានខ្នាតតូចធ្វើអំពីមាសសំរាប់ជូនក្រុមប្រឹក្សាធម្មនុញ្ញ និង ខ្នាតធំធ្វើអំពីប្រាក់សំរាប់ផ្តល់ជូនភ្ញៀវកិត្តិយសរបស់ក្រុមប្រឹក្សាធម្មនុញ្ញ ។

**មាត្រា ១០ .-**

រូបសញ្ញា នៃ ក្រុមប្រឹក្សាធម្មនុញ្ញខ្នាតតូច មានរាងជារង្វង់ពណ៌មាសនៅកណ្តាល ពទ្ធ័ជុំវិញដោយហាមមណ្ឌលពណ៌ខៀវ ។ នៅផ្នែកខាងលើហាមមណ្ឌលមានចារឹកអក្សរខ្មែរ " **ក្រុមប្រឹក្សាធម្មនុញ្ញ** " និង នៅផ្នែកខាងក្រោមមានចារឹកអក្សរអង់គ្លេស " **Constitutional Council** " ។ នៅលើផ្ទៃរង្វង់ពណ៌មាស មាននិមិត្តសញ្ញានៃក្រុម-ប្រឹក្សាធម្មនុញ្ញពណ៌ស ។

រូបសញ្ញា នៃក្រុមប្រឹក្សាធម្មនុញ្ញខ្នាតធំមានរាងជារង្វង់ មាននិមិត្តសញ្ញានៃក្រុមប្រឹក្សាធម្មនុញ្ញ នៅចំកណ្តាល ។ ផ្នែកខាងលើនៃនិមិត្តសញ្ញាក្រុមប្រឹក្សាធម្មនុញ្ញ មានចារឹកអក្សរខ្មែរ " **ក្រុមប្រឹក្សាធម្មនុញ្ញ** " និង នៅផ្នែកខាងក្រោមមានចារឹកអក្សរអង់គ្លេស " Constitutional Council " ឬ អក្សរបារាំង " Conseil Constitutionnel " ។ រង្វង់នេះព័ទ្ធជុំវិញដោយហាមមណ្ឌល ដែលលំអដោយក្បាច់សន្លឹកភ្ញីទេស ។

**មាត្រា ១១ .-**

រូបសញ្ញា នៃ ក្រុមប្រឹក្សាធម្មនុញ្ញទាំងខ្នាតតូច ទាំងខ្នាតធំ មានតម្កល់ទុកនៅអគ្គលេខាធិការដ្ឋានក្រុមប្រឹក្សា-ធម្មនុញ្ញ ( ដូចក្នុងឧបសម្ព័ន្ធទី ៣ នៃ ព្រះរាជក្រឹត្យនេះ ) ។

## ជំពូកទី៤
## អំពីសញ្ញាសក្តិ និង ឯកសណ្ឋាន

**មាត្រា ១២ .-**

បង្កើតសញ្ញាសក្តិ និង ឯកសណ្ឋានសំរាប់សម្គាល់ប្រធាន និង សមាជិកក្រុមប្រឹក្សាធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា។

**មាត្រា ១៣ .-**

សញ្ញាសក្តិ រួមមាន សក្តិស្មា សក្តិចុងកអាវ និង សក្តិចុងដៃអាវ ទាំងសងខាង ។

ឯកសណ្ឋាន រួមមាន ឯកសណ្ឋានធំលេខ ១ ឯកសណ្ឋានធំលេខ ២ និងឯកសណ្ឋានធំលេខ ៣ ។

សញ្ញាសក្តិ និង ឯកសណ្ឋាននេះ ប្រើប្រាស់នៅពេលចូលរួមពិធីបុណ្យប្រពៃណីជាតិ ពិធីបុណ្យជាតិ និង ពិធីផ្លូវការផ្សេង ៗ ។

## ផ្នែកទី ១

## អំពីសញ្ញាសក្តិ

**មាត្រា ១៤ .-**

សញ្ញាសក្តិសំរាប់ប្រធាន និង សមាជិកក្រុមប្រឹក្សាធម្មនុញ្ញ ត្រូវបានកំណត់ដូចតទៅ ÷

**១-សំរាប់ប្រធានក្រុមប្រឹក្សាធម្មនុញ្ញ**

***ក-សក្តិស្មា*** : មានផ្ទៃកម្ទីពណ៌ខ្មៅ ។ នៅខាងដើមនៃតួសក្តិមានឡេវរូបព្រះសង្ខារពណ៌មាសមួយ ដែលមានអង្កត់ផ្ចិតប្រវែង ១.៨០ សង់ទីម៉ែត្រ ។ បន្ទាប់មកមាននិមិត្តសញ្ញាក្រុមប្រឹក្សាធម្មនុញ្ញគង់នៅលើបល្ល័ង្កក្បាច់ត្របកឈូក០៩ សន្លឹកពណ៌មាស ។ នៅផ្នែកខាងចុងនៃតួសក្តិមានតុបតែងដោយក្បាច់ដើមភ្ញីវល្លិ រចនាដោយសន្លឹកពណ៌មាស តំណាងឱ្យដំណាំឧស្សាហកម្ម និង ដំណាំរួមផ្សំនៅកម្ពុជា ។ ឡេវ និមិត្តសញ្ញាក្រុមប្រឹក្សាធម្មនុញ្ញ និង ក្បាច់ដើមភ្ញីវល្លិ ហ៊ុំព័ទ្ធដោយ ÷

- ខ្សែពួរវេញពណ៌មាសបីខ្សែ
- បន្ទាប់មកមានក្បាច់ជរជាយសន្លឹកភ្ញីទេសពណ៌មាសពីរខ្សែវេញចូលគ្នា និង
- នៅរឹមនៃជាយតួសក្តិ មានខ្សែពួរវេញពណ៌មាសធំមួយខ្សែ ។

ខ្នាតសក្តិស្មាមានរាងចតុកោណព្នាយ ដែលត្រូវបានកំណត់ដូចខាងក្រោមនេះ ÷

- បាតធំប្រវែង ៥.៥០ សង់ទីម៉ែត្រ
- បាតតូចប្រវែង ៤.៥០ សង់ទីម៉ែត្រ មានរាងកាត់ជ្រុងសងខាង
- បណ្តោយពីបាតតូចដល់បាតធំប្រវែង ១២.៤០ សង់ទីម៉ែត្រ

***ខ-សក្តិចុងកអាវ*** : មានផ្ទៃកម្ទីពណ៌ខ្មៅ ។ នៅផ្នែកខាងដើម និង ខាងក្រោមតួសក្តិ មាននិមិត្តសញ្ញាក្រុមប្រឹក្សាធម្មនុញ្ញគង់នៅលើបល្ល័ង្កក្បាច់ត្របកឈូក០៩ សន្លឹកពណ៌មាស ។ នៅផ្នែកខាងចុងនៃតួសក្តិមានក្បាច់ដើមភ្ញីវល្លិ៍ រចនាដោយសន្លឹក ផ្លែ ផ្កា ពណ៌មាស ដែលតំណាងឱ្យផលិតផលដំណាំឧស្សាហកម្ម និង ដំណាំរួមផ្សំនៅកម្ពុជា ។ នៅជ្រុងខាងដើម និង ខាងលើនៃរូបទាំងពីរខាងលើនេះមាន ÷

- ខ្សែពួរវេញពណ៌មាសបីខ្សែ
- បន្ទាប់មកមានក្បាច់ជរជាយសន្លឹកភ្ញីទេសពណ៌មាសពីរខ្សែវេញចូលគ្នា និង
- នៅរឹមនៃជាយតួសក្តិមានខ្សែពួរវេញពណ៌មាសធំមួយខ្សែ ។

ខ្នាតសក្តិចុងកអាវត្រូវបានកំណត់ដូចខាងក្រោមនេះ ÷

- មានរាងជាប្រលេឡូក្រាម
- បណ្តោយប្រវែង ៩,៨០ សង់ទីម៉ែត្រ
- ទទឹងប្រវែង ៤,០០ សង់ទីម៉ែត្រ

**គ-សក្តិចុងដៃអាវ :** មានផ្ទៃកម្ចីពណ៌ខ្មៅ ។ នៅផ្ទៃខាងក្រៅ និង ខាងក្រោម មាននិមិត្តសញ្ញាក្រុមប្រឹក្សាធម្មនុញ្ញ គង់នៅលើបល្ល័ង្កក្បាច់គ្របកឈូក ០៩ សន្លឹកពណ៌មាស និង ទ្រដោយក្បាច់កួរស្រូវពណ៌មាសពីរកោងរាងស្លែងក្របីដែលតំណាងឱ្យការបង្កបង្កើនផលស្រូវនៅកម្ពុជា ។ បន្ទាប់មកមានគុបតែងដោយក្បាច់ដើមភ្ញីវល្លិពីរខ្សែព័ន្ធគ្នា រចនាដោយសន្លឹក ផ្លែ ផ្កា ដែលតំណាងឱ្យផលិតផលដំណាំឧស្សាហកម្ម និង ដំណាំរួមផ្សំនៅកម្ពុជា ។ នៅពីលើ និង ពីចំហៀងនៃរូបទាំងនេះមាន ÷

- ខ្សែពួរវេញពណ៌មាសបីខ្សែ
- បន្ទាប់មកមានក្បាច់ជរជាយសន្លឹកភ្ញីទេសពណ៌មាសពីរខ្សែវេញចូលគ្នា និង
- នៅរឹមនៃជាយគូសក្តិ មានខ្សែពួរវេញពណ៌មាសធំមួយខ្សែ ។

ខ្នាតសក្តិចុងដៃអាវទាំងសងខាងមានរាងជាចតុកោណព្នាយ ដែលត្រូវបានកំណត់ដូចខាងក្រោមនេះ ÷

- -បាតធំប្រវែង ៣៣,៧០ សង់ទីម៉ែត្រ
- -បាតតូចប្រវែង ៣១,២០ សង់ទីម៉ែត្រ
- -កំពស់ ៩,២០ សង់ទីម៉ែត្រ

*រូបគំនូរសក្តិស្មា សក្តិចុងកអាវ សំរាប់ប្រធានក្រុមប្រឹក្សាធម្មនុញ្ញមានដូចក្នុងឧបសម្ព័ន្ធទី ៤ និងសក្តិចុងដៃអាវ សំរាប់ប្រធានក្រុមប្រឹក្សាធម្មនុញ្ញមានដូចក្នុងឧបសម្ព័ន្ធទី ៥ នៃព្រះរាជក្រឹត្យនេះ ។*

**២-សំរាប់ប្រធានក្រុមប្រឹក្សាធម្មនុញ្ញ ជាស្ត្រី**

**ក-សក្តិស្មា :** មានលក្ខណៈដូចគ្នាគ្រប់ចំណុចទាំងអស់នៃសក្តិស្មាសំរាប់ប្រធានក្រុមប្រឹក្សាធម្មនុញ្ញជាបុរស ។ ដោយឡែកចំពោះខ្នាតសក្តិស្មារបស់ប្រធានក្រុមប្រឹក្សាធម្មនុញ្ញជាស្ត្រី មានទំហំ ៨០ % ៧៥ % ឬ ៩០ % នៃសក្តិស្មារបស់បុរស អាស្រ័យលើមាឌ របស់ស្ត្រីជាប្រធានក្រុមប្រឹក្សាធម្មនុញ្ញ ។

**ខ-សក្តិចុងកអាវ :** មានលក្ខណៈដូចគ្នាគ្រប់ចំណុចទាំងអស់នៃសក្តិចុងកអាវសំរាប់ប្រធានក្រុមប្រឹក្សាធម្មនុញ្ញជាបុរស ។ ដោយឡែកចំពោះខ្នាតសក្តិចុងកអាវរបស់ប្រធានក្រុមប្រឹក្សាធម្មនុញ្ញជាស្ត្រី មានទំហំពី ៣ ទៅ ៣,៥០ សង់ទីម៉ែត្រ អាស្រ័យលើមាឌរបស់ស្ត្រីជាប្រធានក្រុមប្រឹក្សាធម្មនុញ្ញ ។

**គ-សក្តិចុងដៃអាវ :** មានលក្ខណៈដូចគ្នាគ្រប់ចំណុចទាំងអស់នៃសក្តិចុងដៃអាវសំរាប់ប្រធានក្រុមប្រឹក្សាធម្មនុញ្ញជាបុរស ។ ដោយឡែកចំពោះខ្នាតសក្តិចុងដៃអាវរបស់ប្រធានក្រុមប្រឹក្សាធម្មនុញ្ញជាស្ត្រី អាចមានទំហំទទឹងស្មើនឹង ៧០ ទៅ ៧៥ % នៃសក្តិចុងដៃអាវរបស់បុរស អាស្រ័យលើមាឌរបស់ស្ត្រីជាប្រធានក្រុមប្រឹក្សាធម្មនុញ្ញ ។

**៣-សំរាប់សមាជិកក្រុមប្រឹក្សាធម្មនុញ្ញ**

**ក-សក្តិស្មា** : មានលក្ខណៈដូចគ្នាគ្រប់ចំណុចនៃសក្តិស្មាសំរាប់ប្រធាន លើកលែងតែខ្សែពួរវេញពណ៌មាសព័ទ្ធជុំវិញទ្បេវ និមិត្តសញ្ញាក្រុមប្រឹក្សាធម្មនុញ្ញ និង ក្បាច់ដើមភ្ញីវល្លិ គឺប្រធានក្រុមប្រឹក្សាធម្មនុញ្ញមានបីខ្សែ សមាជិកក្រុមប្រឹក្សាធម្មនុញ្ញមានតែពីរខ្សែ ។

**ខ-សក្តិចុងកអាវ** : មានលក្ខណៈដូចគ្នាគ្រប់ចំណុចនៃសក្តិចុងកអាវសំរាប់ប្រធាន លើកលែងតែខ្សែពួរវេញពណ៌មាសព័ទ្ធពីរជ្រុងនៃក្បាច់ភ្ញីទេស និង និមិត្តសញ្ញាក្រុមប្រឹក្សាធម្មនុញ្ញ គឺប្រធានក្រុមប្រឹក្សាធម្មនុញ្ញមានបីខ្សែ សមាជិកក្រុមប្រឹក្សាធម្មនុញ្ញមានតែពីរខ្សែ ។

**គ-សក្តិចុងដៃអាវ** : មានលក្ខណៈដូចគ្នាគ្រប់ចំណុចនៃសក្តិចុងដៃអាវសំរាប់ប្រធាន លើកលែងតែខ្សែពួរវេញពណ៌មាសព័ទ្ធបីជ្រុងនៃក្បាច់ភ្ញីទេស និង និមិត្តសញ្ញាក្រុមប្រឹក្សាធម្មនុញ្ញ គឺប្រធានក្រុមប្រឹក្សាធម្មនុញ្ញមានបីខ្សែ សមាជិកក្រុមប្រឹក្សាធម្មនុញ្ញមានតែពីរខ្សែ ។

*រូបគំនូរសក្តិស្មា សក្តិចុងកអាវ សំរាប់សមាជិកក្រុមប្រឹក្សាធម្មនុញ្ញមានដូចក្នុងឧបសម្ព័ន្ធទី ៦ និងសក្តិចុងដៃអាវសំរាប់សមាជិកក្រុមប្រឹក្សាធម្មនុញ្ញមានដូចក្នុងឧបសម្ព័ន្ធទី ៧ នៃព្រះរាជក្រឹត្យនេះ ។*

**៤-សំរាប់សមាជិកក្រុមប្រឹក្សាធម្មនុញ្ញ ជាស្ត្រី**

**ក-សក្តិស្មា**: សក្តិស្មាសំរាប់សមាជិកក្រុមប្រឹក្សាធម្មនុញ្ញ ជាស្ត្រី ដូចគ្នាគ្រប់ចំណុចទាំងអស់នៃសក្តិស្មាសំរាប់សមាជិកក្រុមប្រឹក្សាធម្មនុញ្ញ ជាបុរស ។ ដោយឡែកចំពោះខ្នាតសក្តិស្មារបស់ស្ត្រី មានទំហំ៨០ % ៨៥ % ឬ ៩០ % នៃសក្តិស្មារបស់បុរស អាស្រ័យលើមាឌ របស់ស្ត្រីជាសមាជិកក្រុមប្រឹក្សាធម្មនុញ្ញ ។

**ខ-សក្តិចុងកអាវ** : ដូចគ្នាគ្រប់ចំណុចទាំងអស់នៃសក្តិចុងកអាវសំរាប់សមាជិកក្រុមប្រឹក្សាធម្មនុញ្ញ ជាបុរស ។ ដោយឡែកចំពោះខ្នាតសក្តិចុងកអាវរបស់ស្ត្រី មានទទឹងពី ៣ ទៅ ៣,៥០ សង់ទីម៉ែត្រ អាស្រ័យលើមាឌរបស់ស្ត្រីជាសមាជិកក្រុមប្រឹក្សាធម្មនុញ្ញ ។

**គ-សក្តិចុងដៃអាវ**: ដូចគ្នាគ្រប់ចំណុចទាំងអស់នៃសក្តិចុងដៃអាវសំរាប់សមាជិកក្រុមប្រឹក្សាធម្មនុញ្ញជាបុរស ។ ដោយឡែកចំពោះខ្នាតសក្តិចុងដៃអាវរបស់ស្ត្រី អាចមានទំហំទទឹងស្មើនឹង ៧០ ទៅ ៧៥ % នៃសក្តិចុងដៃអាវរបស់បុរស អាស្រ័យលើមាឌរបស់ស្ត្រីជាសមាជិកក្រុមប្រឹក្សាធម្មនុញ្ញ ។

## ផ្នែកទី ២
## អំពីប្រភេទឯកសណ្ឋាន និង ការប្រើប្រាស់

**មាត្រា ១៥ .-**

ប្រភេទឯកសណ្ឋានសំរាប់ក្រុមប្រឹក្សាធម្មនុញ្ញ ត្រូវបានកំណត់ដូចខាងក្រោម -

## ១_ឯកសណ្ឋានធំលេខ ១

**-សណ្ឋានអាវបុរស**

អាវកុដពណ៌ស កត្រង់ កាត់រាងអាវធំគ្មានផែកខ្នង ចុងកអាវទាំងសងខាងមានសក្តិកអាវ មានបន្ទះលើស្មាសំរាប់ដាក់សក្តិមួយគូ ដៃអាវវែង ចុងដៃអាវមានសក្តិ មានហោប៉ៅចោះចំនួន ៤ នៅខាងលើពីរដែលមានគម្របរាងស្លឹកពោធិស្រួចចំកណ្តាល ចោះរន្ធឡេវសំរាប់បិទ មានឡេវរូបព្រះសង្ហារពណ៌មាស ដែលមានអង្កត់ផ្ចិតប្រវែង ១.៨០សង់ទីម៉ែត្រ ហោប៉ៅពីរខាងក្រោមមានគម្របរាងចតុកោណកែង និងគ្មានឡេវ ។ អាវបិទឡេវមុខដោយមានដាក់ឡេវរូបព្រះសង្ហារពណ៌មាស ចំនួន ៧ ដែលឡេវនិមួយៗមានអង្កត់ផ្ចិតប្រវែង ២.៥០ សង់ទីម៉ែត្រ ។

**-សណ្ឋានអាវស្ត្រី**

អាវជីបរាង ពណ៌ស កត្រង់ ដោយប្រើសាច់ក្រណាត់ដូចឈុតអាវបុរសដែរ គ្មានផែកខ្នង បិទឡេវមុខមានដាក់ឡេវរូបព្រះសង្ហារចំនួន ៥ មានអង្កត់ផ្ចិតប្រវែង ២.៥០ សង់ទីម៉ែត្រ និងមានរាងមូលនៅជាយខាងក្រោម ។ មានបន្ទះលើស្មាសំរាប់ដាក់សក្តិ ចុងកអាវទាំងសងខាងមានសក្តិចុងកអាវ ដៃអាវវែងត្រឹមភ្នែកគោលដៃ ចុងដៃអាវមានសក្តិ។ អាវមានហោប៉ៅចោះចំនួន ២ នៅខាងក្រោម ដោយមានគម្របរាងចតុកោណកែង និងគ្មានឡេវ ។

**-សណ្ឋានសំពត់បុរស និង ស្ត្រី**

សំពត់ផាមួងចងក្បិន ពណ៌តាមថ្ងៃ ។

**-សណ្ឋានស្បែកជើងបុរស**

ស្បែកជើងឃ្លុបពណ៌ខ្មៅកខ្លី មានចងខ្សែ និងស្រោមជើងពណ៌ខ្មៅដល់ជង្គង់ ។

**-សណ្ឋានស្បែកជើងស្ត្រី**

ស្បែកជើងឃ្លុបពណ៌ស កខ្លី គ្មានចងខ្សែ កែងខ្ពស់ ។

*រូបគំនូរឯកសណ្ឋានធំលេខ ១ សំរាប់ក្រុមប្រឹក្សាធម្មនុញ្ញ ជាបុរស មានដូចក្នុងឧបសម្ព័ន្ធទី៨ និងសំរាប់ក្រុម-ប្រឹក្សាធម្មនុញ្ញ ជាស្ត្រី មានដូចក្នុងឧបសម្ព័ន្ធទី ៩ នៃព្រះរាជក្រឹត្យនេះ ។*

ឯកសណ្ឋានធំលេខ ១ នេះ សំរាប់ប្រើក្នុងពិធីស្បថចូលកាន់តំណែង បុណ្យប្រពៃណីជាតិ និងសាសនា ដែលប្រារព្ធធ្វើឡើងនៅក្នុងព្រះបរមរាជវាំង ក្នុងវត្តអារាម និងទីកន្លែងផ្សេងៗ ។

ឯកសណ្ឋានប្រពៃណី ត្រូវស្លៀកពាក់ទៅតាមការកំណត់របស់គណៈកម្មការអចិន្ត្រៃយ៍រៀបចំបុណ្យជាតិ-អន្តរជាតិ ឬ តាមការកំណត់របស់ក្រសួងព្រះបរមរាជវាំង ។

## ២_ឯកសណ្ឋានធំលេខ ២

**-សណ្ឋានអាវបុរស និង ស្ត្រី**

ដូចគ្នាគ្រប់ចំណុចទាំងអស់នៃឯកសណ្ឋានធំលេខ១ ត្រង់ចំណុចសណ្ឋានអាវបុរស និង សណ្ឋានអាវស្ត្រី ។

-សណ្ឋានខោបុរស

ខោជើងវែងពណ៌ស គចង្កេះ ក្លិបកក្រោយខាងឆ្វេង ២ ខាងស្តាំ ២ ហោប៉ៅចំហៀងទៅសងខាង ហោ-ប៉ៅចោះក្រោយ ១ នៅខាងស្តាំ ។

-សណ្ឋានសំពត់ស្ត្រី

សំពត់អំពីផាមូងពណ៌ខៀវចាស់ ចាក់ជើងខ្សែសយពណ៌ប្លាទីនមាស តាមក្បាច់ជរជើងឯកភាពគ្នា ។

-សណ្ឋានស្បែកជើងបុរស-ស្ត្រី

ស្បែកជើងបុរសឃ្លុបពណ៌ខ្មៅកខ្លី មានចងខ្សែ និងស្រោមជើងពណ៌ខ្មៅធម្មតា ។ ស្បែកជើងស្ត្រីមានសណ្ឋានដូចគ្នានឹងឯកសណ្ឋានធំលេខ ១ ដែរ ។

រូបគំនូរឯកសណ្ឋានធំលេខ ២ សំរាប់ក្រុមប្រឹក្សាធម្មនុញ្ញជាបុរស មានដូចក្នុងឧបសម្ព័ន្ធទី៨ និងសំរាប់ក្រុម-ប្រឹក្សាធម្មនុញ្ញជាស្ត្រី មានដូចក្នុងឧបសម្ព័ន្ធទី ៩ នៃព្រះរាជក្រឹត្យនេះ ។

ឯកសណ្ឋានធំលេខ២ នេះសំរាប់ប្រើក្នុងឱកាសទទួលគ្រឿងឥស្សរិយយស ទិវាបុណ្យជាតិ និងអន្តរជាតិនានា។

### ៣-ឯកសណ្ឋានធំលេខ ៣

-សណ្ឋានអាវបុរស និង ស្ត្រី

ដូចគ្នាគ្រប់ចំណុចទាំងអស់នៃឯកសណ្ឋានធំលេខ១ ត្រង់ចំណុចសណ្ឋានអាវបុរស និងសណ្ឋានអាវស្ត្រី តែមានពណ៌ខៀវចាស់។

-សណ្ឋានខោបុរស

មានសណ្ឋានដូចគ្នាទាំងអស់ នៃ ឯកសណ្ឋានធំលេខ ២ ខុសត្រង់ពណ៌ខៀវចាស់ ដូចពណ៌អាវ ។

-សណ្ឋានសំពត់ស្ត្រី

សំពត់សំឡុយពណ៌ខៀវចាស់ ដោយប្រើសាច់ក្រណាត់ដូចឈុតអាវ ។

-សណ្ឋានស្បែកជើងបុរស និង ស្ត្រី

ដូចគ្នាក្នុងឯកសណ្ឋានធំលេខ ២ ។ ចំណែកស្បែកជើងស្ត្រី ប្រើគ្រប់ឯកសណ្ឋានទាំង ៣ ប្រភេទ ។

រូបគំនូរឯកសណ្ឋានធំលេខ ៣ សំរាប់ក្រុមប្រឹក្សាធម្មនុញ្ញជាបុរស មានដូចក្នុងឧបសម្ព័ន្ធទី ៨ និងសំរាប់ក្រុម-ប្រឹក្សាធម្មនុញ្ញ ជាស្ត្រី មានដូចក្នុងឧបសម្ព័ន្ធទី ៩ នៃព្រះរាជក្រឹត្យនេះ ។

ឯកសណ្ឋានធំលេខ ៣ នេះ សំរាប់ប្រើក្នុងឱកាសទទួលគណៈប្រតិភូជាន់ខ្ពស់ជាតិ-អន្តរជាតិនានា និងបំពេញបេសកកម្មនៅក្រៅប្រទេស ។

## ជំពូកទី៥

## អវសានប្បញ្ញត្តិ

**មាត្រា ១៦ ._**

ការចំណាយសំរាប់ផលិតរូបសញ្ញា សញ្ញាសក្តិ និង ឯកសណ្ឋានគ្រប់ប្រភេទរបស់ក្រុមប្រឹក្សាធម្មនុញ្ញ ជាបន្ទុកក្នុងថវិការបស់ក្រុមប្រឹក្សាធម្មនុញ្ញ ។

**មាត្រា ១៧ ._**

សញ្ញាសក្តិ និង ឯកសណ្ឋានគ្រប់ប្រភេទរបស់ក្រុមប្រឹក្សាធម្មនុញ្ញមានគំរូរក្សាទុកនៅអគ្គលេខាធិការដ្ឋានក្រុម-ប្រឹក្សាធម្មនុញ្ញ ។

**មាត្រា ១៨ ._**

រាល់បទប្បញ្ញត្តិទាំងឡាយណា ដែលផ្ទុយពីព្រះរាជក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

**មាត្រា ១៩ ._**

ប្រធានក្រុមប្រឹក្សាធម្មនុញ្ញ ត្រូវទទួលអនុវត្តព្រះរាជក្រឹត្យនេះចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ ។

ព្រះហស្តលេខា

**នរោត្តម សីហនុ**

ធ្វើនៅរាជធានីភ្នំពេញ,ថ្ងៃទី ១១ ខែ តុលា ឆ្នាំ ២០០១

លេខ : ០០១ ចល

**ដើម្បីចម្លងចែកផ្សាយ**

រាជធានីភ្នំពេញ,ថ្ងៃទី ១៦ ខែ តុលា ឆ្នាំ ២០០១

**អគ្គលេខាធិការក្រុមប្រឹក្សាធម្មនុញ្ញ**

**ពិន តាំងសាន**

ឧបសម្ព័ន្ធ ១ នៃព្រះរាជក្រឹត្យលេខ នស/រកត/១០០១/៣៥៩ ចុះថ្ងៃទី ១១ ខែ តុលា ឆ្នាំ ២០០១
ស្តីពីនិមិត្តសញ្ញា ត្រា រូបសញ្ញា សញ្ញាសក្តិ និង ឯកសណ្ឋាននៃក្រុមប្រឹក្សាធម្មនុញ្ញ

# និមិត្តសញ្ញា នៃ ក្រុមប្រឹក្សាធម្មនុញ្ញ



**ឧបសម្ព័ន្ធទី ២ នៃព្រះរាជក្រឹត្យលេខ នស/រកត/១០០១/៣៥៥ ចុះថ្ងៃទី ១១ ខែ តុលា ឆ្នាំ២០០១**
**ស្តីពីនិមិត្តសញ្ញា ត្រា រូបសញ្ញា សញ្ញាសក្តិ និង ឯកសណ្ឋាននៃក្រុមប្រឹក្សាធម្មនុញ្ញ**

**ត្រារបស់ក្រុមប្រឹក្សាធម្មនុញ្ញ**



- រង្វង់ខាងក្រៅមានអង្កត់ផ្ចិតប្រវែង ៤.៦ cm និង រង្វង់ខាងក្នុងមានអង្កត់ផ្ចិតប្រវែង ៣.២ cm

**ឧបសម្ព័ន្ធទី ៣ នៃព្រះរាជក្រឹត្យលេខ នស/រកត/១០០១/៣៥៨ ចុះថ្ងៃទី ខែ ឆ្នាំ២០០១**
**ស្ដីពីនិមិត្តសញ្ញា ត្រា រូបសញ្ញា សញ្ញាសក្តិ និង ឯកសណ្ឋាននៃក្រុមប្រឹក្សាធម្មនុញ្ញ**

# រូបសញ្ញានៃក្រុមប្រឹក្សាធម្មនុញ្ញ

## ខ្នាតតូច




២ cm

- រង្វង់ខាងក្រៅមានអង្កត់ផ្ចិតប្រវែង ២ cm និងរង្វង់ពណ៌មាសខាងក្នុង មានអង្កត់ផ្ចិតប្រវែង ១.៦ cm

## ខ្នាតធំ

១២ cm







- រង្វង់ខាងក្រៅមានអង្កត់ផ្ចិតប្រវែង ១២ cm និងរង្វង់ខាងក្នុងមានអង្កត់ផ្ចិតប្រវែង ១០ cm

ឧបសម្ព័ន្ធនៃព្រះរាជក្រឹត្យលេខ នស/រកត/១០០១/៣៤៥ ចុះថ្ងៃទី ១១ ខែ តុលា ឆ្នាំ២០០១

ប្រធានក្រុមប្រឹក្សាធម្មនុញ្ញ

ទាក់ទងនឹងគ្រឿងឥស្សរិយយស សក្តិ និង ឯកសណ្ឋាននៃក្រុមប្រឹក្សាធម្មនុញ្ញ



សក្តិស្មា



សក្តិចុងកអាវ

**ឯកសណ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ**

ឧបសម្ព័ន្ធទី៥ នៃព្រះរាជក្រឹត្យលេខ នស/រកត/១០០១/៣៤៨ ចុះថ្ងៃទី១១ ខែតុលា ឆ្នាំ២០០១
ស្តីពីនិមិត្តសញ្ញា ត្រា រូបសញ្ញា សញ្ញាសក្តិ និង ឯកសណ្ឋាននៃក្រុមប្រឹក្សាធម្មនុញ្ញ



## សក្តិចុងដៃអាវ



នស/រកត/១០០១/៧៥៥ ... ១១ ខែតុលា ឆ្នាំ២០០១

សមាជិកក្រុមប្រឹក្សាធម្មនុញ្ញ

សក្តិស្មា





សក្តិចុងកអាវ

**សមាជិកក្រុមប្រឹក្សាធម្មនុញ្ញ**

ឧបសម្ព័ន្ធទី៧ នៃព្រះរាជក្រឹត្យលេខ នស/រកត/១០០៧/៣៥៩ ចុះថ្ងៃទី១១ ខែតុលា ឆ្នាំ២០០១

**ស្ដីពីនិមិត្តសញ្ញា ត្រា រូបសញ្ញា សញ្ញាសក្តិ និង ឯកសណ្ឋាននៃក្រុមប្រឹក្សាធម្មនុញ្ញ**



សក្តិចុងដៃអាវ



**ឧបសម្ព័ន្ធទី៨ នៃព្រះរាជក្រឹត្យលេខ នស/រកត/១០០១/៣៥៩ ចុះថ្ងៃទី ១១ ខែ តុលា ឆ្នាំ២០០១**
**ស្តីពីនិមិត្តសញ្ញា ត្រា រូបសញ្ញា សញ្ញាសក្តិ និង ឯកសណ្ឋាននៃក្រុមប្រឹក្សាធម្មនុញ្ញ**

**សំរាប់ប្រធាន និង សមាជិកក្រុមប្រឹក្សាធម្មនុញ្ញ ជាបុរស**

**ឯកសណ្ឋានធំលេខ ១**



**ឯកសណ្ឋានធំលេខ ២**



**ឯកសណ្ឋានធំលេខ ៣**



ឧបសម្ព័ន្ធទី៩ នៃព្រះរាជក្រឹត្យលេខ នស/រកត/១០០១/៣៥៩ ចុះថ្ងៃទី ១១ ខែ តុលា ឆ្នាំ២០០១
ស្តីពីនិមិត្តសញ្ញា ត្រា រូបសញ្ញា សញ្ញាសក្តិ និង ឯកសណ្ឋាននៃក្រុមប្រឹក្សាធម្មនុញ្ញ

សំរាប់ប្រធាន និង សមាជិកក្រុមប្រឹក្សាធម្មនុញ្ញ ជានារី

ឯកសណ្ឋានធំលេខ ១



ឯកសណ្ឋានធំលេខ ២



ឯកសណ្ឋានធំលេខ ៣

